ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ០១ ជស៩៥

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួល សមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង ឯកឧត្តម រដ្ឋមន្ត្រី ក្រសួង ការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## ប្រកាសឱ្យប្រើ

— ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពី-ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាមិត្តភាព និង សហប្រតិបត្តិការនៅអាស៊ីអគ្នេយ៍ ដែលមាន សេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់

## ស្តីពី

## ការផ្តល់សច្ចាប័នលើ
## សន្ធិសញ្ញាមិត្តភាព
## និង
## សហប្រតិបត្តិការនៅអាស៊ីអគ្នេយ៍

# ច្បាប់

## ស្ដីពី

## ការផ្ដល់សច្ចាប័នលើ

## សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអគ្នេយ៍

មាត្រា ១.- យល់ព្រមលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអគ្នេយ៍ ធ្វើនៅដិនប៉ាសាបាលី ប្រទេសឥណ្ឌូនេស៊ី កាលពីថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៧៦ ដូចដែលមានអត្ថបទភ្ជាប់ជាមួយ ។

មាត្រា ២.-រាជរដ្ឋាភិបាលកម្ពុជាត្រូវបន្តនីតិវិធី ក្រោយពីបានចុះហត្ថលេខា លើលិខិតុបករណ៍នៃការចូលរួមក្នុងសន្ធិសញ្ញាខាងលើ ដើម្បីបញ្ចូលព្រះរាជាណាចក្រកម្ពុជាក្នុងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ ហៅកាត់ថា អាស៊ាន ។

មាត្រា ៣.-ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា**

**ជា ស៊ីម**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១**

ព្រះហស្ថលេខា

**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី២**

ហត្ថលេខា

**ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រីទី១ និង ទី២

**រដ្ឋមន្ត្រីក្រសួងការបរទេស**

**និងសហប្រតិបត្តិការអន្តរជាតិ**

ហត្ថលេខា

**អ៊ុង ហួត**

លេខ .៣៩. ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កក្កដា ឆ្នាំ ១៩៩៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ អាន**